**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិស្តីពី "ការពង្រឹងដំណើរការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា"

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងចំពោះសាធារណជន កម្មករ និយោជិត និយោជក អង្គការវិជ្ជាជីវៈ អង្គការជាតិ និងអន្តរជាតិឱ្យបានជ្រាបថា កាលពីថ្ងៃទី២៤-២៥ ខែមេសា ឆ្នាំ២០១៤ មានការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិស្តីពី "ការពង្រឹងដំណើរការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា" ក្រោមការឧបត្ថម្ភជំនួយបច្ចេកទេសរបស់អង្គការអន្តរជាតិខាងការងារ (ILO)។

អង្គសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីនេះ មានការចូលរួមធ្វើបទបង្ហាញពីអ្នកជំនាញជាន់ខ្ពស់ខាងប្រាក់ឈ្នួល នៃការិយាល័យអង្គការអន្តរជាតិខាងការងារ (ILO) ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ហើយទទួលបានលទ្ធផល និងសំណើ ដូចខាងក្រោម៖

១-អំពីភាពញឹកញាប់នៃការកែសម្រួលប្រាក់ឈ្នួល៖ ពិភាក្សាកែសម្រួលប្រចាំឆ្នាំ។

២-អំពីភាពអាចព្យាករណ៍បាននៃការកែសម្រួលប្រាក់ឈ្នួលអប្បបរមា៖ យកជម្រើសកំណើនតាមលំដាប់បន្តបន្ទាប់។

៣-អំពីយន្តការនៃការចរចា៖ យកជម្រើសគោលការណ៍ឈ្នះ-ឈ្នះ ក្នុងការដោះស្រាយបញ្ហា។

៤-អំពីបែបបទនៃការធ្វើសេចក្តីសម្រេចចិត្ត៖ ភាគច្រើនជ្រើសរើសយកយន្តការកុងសង់ស៊ីស និងមួយចំនួនជ្រើសរើសយកសម្លេងភាគច្រើនតាមរយៈការបោះឆ្នោតសម្ងាត់។

៥-អំពីការប្រើប្រាស់ទិន្នន័យ និងលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការកែសម្រួល៖ ប្រើប្រាស់ទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ និងយកលក្ខណៈវិនិច្ឆ័យបែបសេដ្ឋកិច្ច និងសង្គម។ លក្ខណៈវិនិច្ឆ័យបែបសេដ្ឋកិច្ចមាន៖ ផលិតភាព ភាពប្រកួតប្រជែង ស្ថានភាពទីផ្សារការងារ និងកម្រិតចំណេញរបស់វិស័យ។ លក្ខណៈវិនិច្ឆ័យបែបសង្គមមាន៖ ស្ថានភាពគ្រួសារ អត្រាអតិផរណា និងការចំណាយក្នុងការរស់នៅ។

ក្រៅពីនេះ អង្គសិក្ខាសាលាក៏បានឯកភាពជាគោលការណ៍ដែរថា បើទោះបីមានគោលការណ៍ និងរូបមន្តណាមួយដែលផលិតបានជាតួលេខណាមួយក៏ដោយ តួលេខនោះគ្រាន់តែជាតួលេខយោងសម្រាប់ដាក់ជូនគណៈកម្មការប្រឹក្សាការងារពិភាក្សាជាផ្លូវការតែប៉ុណ្ណោះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន កម្មករនិយោជិត និយោជក អង្គការវិជ្ជាជីវៈ អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤